# រឿង បុរស ២ នាក់ ទាស់គ្នាពីការជីកអណ្តូង

មាននិទានមួយដំណាលថា : មានបុរស ២ នាក់នាំគ្នាទៅជីកអណ្តូង លុះជីកជ្រៅទៅប្រទះឃើញមាសមួយពិន្ទង គឺបុរសមួយជីកត្រូវមាត់ពិន្ទងម្ខាង បុរសមួយទៀត ក៏ជីកត្រូវមាត់ ពិន្ទងម្ខាងដែរ ហើយបារយកមាសមកចែកស្មើគ្នា នៅតែពិន្ទងដែលដាក់មាស ចែកគ្នាមិនដាច់ស្រេចសោះ ថៅមួយថា “ ត្រូវឲ្យពិន្ទងនេះមកអញ ” ។ ឯថៅមួយថា “ អញជីកត្រូវស្មើគ្នាដែរ ម្តេចក៏ត្រូវបានតែម្នាក់ឯង គួរបានអញផង ” ។ ថៅទាំងពីរនាក់ប្រកែកជជែកគ្នាពុំដាច់ស្រេច ទើបនាំសេចក្តីទៅប្តឹងថៅក្រម ១ ជម្រះជំនុំទៅថា “ ត្រូវបំបែកពិន្ទងនេះចែកគ្នា ” ។ ថៅទាំងពីរនាក់ពុំសុខចិត្ត ទើបថៅក្រមនាំថៅទាំង ២ នាក់ ឡើងទៅក្រាបទូលព្រះមហាក្សត្រតាមដោយដំណើរនោះ ។ ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលដណ្តឹងទៅថៅទាំង ២ នាក់នោះ ថា “ មាសនិងពិន្ទងនេះ ព្រះស្តែងបានមកពីណា ? ” ។ ថៅទាំងពីរនាក់ក្រាបបង្គំទូលព្រមគ្នាថា “ សូមទ្រង់ព្រះមេត្តាប្រោស ត្បិតខ្ញុំព្រះបាទ អម្ចាស់ទាំង ២ នាក់នេះ នាំគ្នាទៅជីកអណ្តូងត្រូវលើមាត់ពិន្ទងមាសព្រមគ្នា ” ។ ព្រះមហាក្សត្រទ្រង់ត្រាស់ដណ្តឹងទៅទៀតថា “ កាលព្រះស្តែងទៅជីកអណ្តូងនោះ តើនរណាបបួលទៅជីកមុន ? ” ។ ថៅមួយក្រាបទូលថា “ ថៅនេះបបួលខ្ញុំព្រះបាទអម្ចាស់មុន ” ។ ឯថៅមួយក៏ក្រាបទូលថា “ ខ្ញុំព្រះបាទអម្ចាស់បបួលថៅនេះមែន ” ។ ព្រះមហាក្សត្រទ្រង់យល់ថា “ ថៅអ្នកបបួលមុននោះ ត្រូវបានចំណែកលើសគេ ” ហើយព្រះអង្គឲ្យយកមាសនោះមកចែកជា ៣ ភាគ ភាគ ២ និងពិន្ទងនោះ ឲ្យបានទៅថៅដែលបបួលនោះ ១ ភាគទៀតឲ្យបានទៅថៅដែលគេបបួលនោះ ។

ព្រះមហាក្សត្រទ្រង់វិនិច្ឆ័យសេចក្តីដូច្នេះហើយ ថៅទាំងពីរនាក់សុខចិត្ត ក៏ថ្វាយបង្គំលាទៅផ្ទះអាត្មាទីទៃ ៗ ហោង ។